H15:00-3150

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងមហាផ្ទៃ

លេខ: ៤១៥៧ សរ

រាជធានីភ្នំពេញថ្ងៃទី០៧ខែវិច្ឆិកាឆ្នាំ២០១២

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ៖** សំណើសុំគោលការណ៍អនុញ្ញាតក្នុងការបន្តពង្រឹង និងពង្រីកការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅតាមក្រុង ស្រុក ខណ្ឌ។

**យោង៖** - គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈរបស់រាជរដ្ឋាភិបាល ដែលត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦

- សេចក្តីសម្រេចលេខ១២សសរ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ក្រុង ស្រុក ខណ្ឌ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ** មេត្តាជ្រាបថា ការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ ត្រូវបានបង្កើតសាកល្បងនៅក្រុងចំនួនពីរ(ក្រុងបាត់ដំបងនៃខេត្តបាត់ដំបង និងក្រុងសៀមរាបនៃខេត្តសៀមរាប) តាមរយៈគម្រោងជំនួយរបស់សហគមអឺរ៉ុប ក្រោមការសម្របសម្រួលរបស់មូលនិធិខុនរ៉ាដអាឌិនណៅអ៊ែរប្រចាំកម្ពុជាតាំងពីឆ្នាំ២០០៥មក។ ចាប់ពីឆ្នាំ២០១០មក ការិយាល័យទាំងពីរនេះ ត្រូវបាននិងកំពុងបង្កើតបន្ថែមទៅបណ្តាក្រុង ស្រុក ខណ្ឌគោលដៅចំនួន៣១ទៀតតាមរយៈគម្រោងដែលផ្តល់ហិរញ្ញប្បទានរួមគ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារពិភពលោក ដែលក្នុងនោះការិយាល័យច្រកចេញចូលតែមួយនិងការិយាល័យប្រជាពលរដ្ឋនៃក្រុង ស្រុកចំនួន១៧ បានដាក់ឲ្យដំណើរការរួចហើយតាំងពីឆ្នាំ២០១០និងឆ្នាំ២០១១។ ចំពោះការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៃក្រុង ស្រុក ខណ្ឌចំនួន១៦ទៀត(ក្រុងចំនួន១០ ខណ្ឌចំនួន០៥ និងស្រុកជនបទចំនួន០១)នឹងត្រូវដាក់ឲ្យដំណើរការនាចុងឆ្នាំ២០១២និងពាក់កណ្តាលឆ្នាំ២០១៣ខាងមុខនេះ។

តាមផែនការដែលបានគ្រោងក្នុងក្របខ័ណ្ឌនៃគម្រោងដែលផ្តល់ហិរញ្ញប្បទានពីធនាគារពិភពលោក ការកសាងអគារការិយាល័យច្រកចេញចូលតែមួយចំនួន៩នៅខណ្ឌទាំង៩នៃរាជធានីភ្នំពេញនឹងត្រូវរៀបចំឡើងក្នុងឆ្នាំ២០១២-២០១៣នេះ។ ប៉ុន្តែដោយសារតែមានការកាត់ថវិកាចេញពីគម្រោង

ដើម្បីធ្វើការសងទូទាត់ទៅឲ្យធនាគារពិភពលោកវិញ សម្រាប់ការចំណាយលើការរៀបចំគម្រោងលើកកំពស់ជីវភាពនិងពង្រឹងសមាគមគ្រួសារក្រីក្រ (LEAP) ដែលមិនត្រូវបានអនុម័តដោយធនាគារពិភពលោក អគារការិយាល័យនេះ ត្រូវបានកាត់បន្ថយមកនៅត្រឹមចំនួន៥ខណ្ឌវិញ។

ផ្អែកតាមកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារពិភពលោក ការចំណាយប្រតិបត្តិការសម្រាប់ការិយាល័យទាំងនេះ នឹងត្រូវទទួលខុសត្រូវដោយរាជរដ្ឋាភិបាលចាប់ពីខែកក្កដាឆ្នាំ ២០១២នេះតទៅរហូតដល់ពេលវេលានៃការបញ្ចប់គម្រោងនាខែមីនា ឆ្នាំ២០១៣។ បច្ចុប្បន្ននេះ ការិយាល័យទាំងអស់ដែលបានបង្កើតនិងដាក់ឲ្យដំណើរការរួចហើយ បាននិងកំពុងប្រតិបត្តិការដោយប្រើប្រាស់ថវិកាបដិភាគរបស់រាជរដ្ឋាភិបាលដែលបានឯកភាព។

តាមរយៈកិច្ចប្រតិបត្តិការរបស់ការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ ដែលបានពង្រីកទៅក្រុង ស្រុកនានានៃខេត្តគោលដៅទាំងអស់នេះ បានបង្ហាញឲ្យឃើញពីការពេញចិត្ត និងការគាំទ្រយ៉ាងទូលំទូលាយពីប្រជាពលរដ្ឋ និងអំពីប្រសិទ្ធភាពនៃការផ្តល់សេវារដ្ឋបាលសាធារណៈចាំបាច់មួយចំនួនប្រកបដោយតម្លាភាព និងទាន់ពេលវេលារបស់ការិយាល័យទាំងនេះជូនប្រជាពលរដ្ឋ និងអាជីវករនានា។ ដោយឡែក ការផ្តល់សេវាកម្មលើមុខងារមួយចំនួនដែលត្រូវបានធ្វើប្រតិភូកម្មទៅឲ្យក្រុង ស្រុកគោលដៅ មានចំនួនកាន់តែច្រើនឡើងពីក្រសួង ស្ថាប័ននានា ដែលបច្ចុប្បន្ននេះមានក្រសួង ស្ថាប័នចំនួន១០បានធ្វើប្រតិភូកម្មលើមុខងារចំនួនជាង៣០មុខងារ និងជាង២០០ប្រភេទសេវាកម្មទៅឲ្យក្រុង ស្រុកគោលដៅដែលមានការិយាល័យច្រកចេញចូលតែមួយ។ ប្រព័ន្ធនៃការផ្តល់សេវាតាមការិយាល័យច្រកចេញចូលតែមួយដែលបានរៀបចំនេះ បានរួមចំណែកកាត់បន្ថយការិយាធិបតេយ្យ និងការយកកំរៃសេវានានាមិនត្រឹមត្រូវលើសពីការកំណត់ផងដែរ។ម្យ៉ាងទៀត កិច្ចដំណើរការនេះក៏ជាមូលដ្ឋានយ៉ាងសំខាន់ សម្រាប់ការពិចារណាទៅលើកិច្ចដំណើរការជំរុញឲ្យមានការផ្ទេរមុខងារជាក់លាក់នានាទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កើនឡើងនូវប្រសិទ្ធភាព និងភាពសក្តិសិទ្ធិនៃការផ្តល់សេវាសាធារណៈ និងការទទួលខុសត្រូវកាន់តែច្បាស់លាស់របស់រដ្ឋបាលមូលដ្ឋាន ចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ដើម្បីធានាបាននូវនិរន្តរភាពនៃការិយាល័យទាំងនេះបន្ទាប់ពីគម្រោងត្រូវបានបញ្ចប់ ខ្ញុំសូមគោរពស្នើសុំគោលការណ៍ដូចខាងក្រោមៈ

១- បង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅខណ្ឌទាំង៤ នៃរាជធានីភ្នំពេញដែលត្រូវបានកាត់ចេញពីក្របខ័ណ្ឌនៃគម្រោងដែលផ្តល់ហិរញ្ញប្បទានដោយធនាគារពិភពលោក ដោយប្រើប្រាស់ថវិការបស់រាជរដ្ឋាភិបាល

២- បន្តគាំទ្រលើចំណាយប្រតិបត្តិការរបស់ការិយាល័យទាំងអស់ដែលត្រូវបានបង្កើត និងត្រៀមបង្កើតដោយថវិការបស់រាជរដ្ឋាភិបាល។ ការចំណាយនេះនឹងត្រូវដាក់បញ្ចូលទៅថវិកាក្រុង ស្រុក និងថវិការាជធានីភ្នំពេញសម្រាប់ខណ្ឌទាំងអស់នៃរាជធានីភ្នំពេញ

៣- បន្តប្រើប្រាស់យន្តការនានាដែលបានបង្កើតឡើងរួចហើយក្នុងពេលអនុវត្តគម្រោងកន្លង មកសម្រាប់គាំទ្រផ្នែកគោលនយោបាយនិងបច្ចេកទេសដល់ការិយាល័យច្រកចេញចូល តែមួយដូចជាគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ ក្រោមជាតិ(គ.ជ.អ.ប) ក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួង និងរៀបចំឲ្យមាន អង្គភាព ឬការិយាល័យអចិន្ត្រៃយ៍មួយចំណុះអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួង មហាផ្ទៃ ដើម្បីសម្របសម្រួល និងគាំទ្រដល់ដំណើរការអនុវត្តនៃការិយាល័យច្រកចេញ ចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ។

អាស្រ័យហេតុនេះ សូម**សម្តេចនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ សម្រេច និងផ្តល់អនុសាសន៍ ដឹកនាំដ៏ខ្ពង់ខ្ពស់។

សូម**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មេត្តា ទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធាន គ.ជ.អ.ប**

**ស ខេង**